# មន្ទីរពាណិជ្ជកម្មសូមស្វាគមន៍

## ប្រភេទអាជ្ញាប័ណ្ណផ្ដល់ជូននៅទីនេះមានៈ

| ប្រភេទអាជ្ញាប័ណ្ណ | អាជីវកម្មប្រភេទណាគួរតែដាក់ពាក្យសុំអាជ្ញាប័ណ្ណនេះ? | តើអាជ្ញាប័ណ្ណនេះប្រើដើម្បីគោលបំណងអ្វី? | តើឯកសារអ្វីខ្លះតំរូវអោយភ្ជាប់ជាមួយ? | តើត្រូវចំណាយរយៈពេលប៉ុន្មានដើម្បីធ្វើអាជ្ញាប័ណ្ណនេះ? | តើពេលណាទើបអាជ្ញាប័ណ្ណអស់សុពលភាព? | តើត្រូវបង់ប្រាក់ប៉ុន្មាន? |
|---|---|---|---|---|---|---|
| លិខិតអនុញ្ញាតធ្វើអាជីវកម្ម | អាជីវកម្ម ពាណិជ្ជកម្ម សេវាកម្ម ទុនក្រោម ១ លាន ដុល្លាអាមេរិក | ដើម្បីផ្ដល់លិខិតអនុញ្ញាតអោយក្រុមហ៊ុនដែលមិនជាប់ពន្ធលើប្រាក់ចំណេញ | ▪ ពាក្យស្នើសុំដែលអនុញ្ញាតដោយអាជ្ញាធរមូលដ្ឋាន ដើម្បីបើកអាជីវកម្មៈ ០១ ច្បាប់<br>▪ អត្តសញ្ញាណប័ណ្ណ រឺលិខិតឆ្លងដែនរបស់ម្ចាស់អាជីវកម្ម ( ថតចំលង )ៈ ០១ ច្បាប់<br>▪ រូបថតចំពីមុខ ទំហំ (៤x៦)ៈ ០៣ សន្លឹក<br>▪ ប័ណ្ណប៉ាតង់ ( ថតចម្លង)ៈ ០១ ច្បាប់ | ២-៤ សប្ដាហ៍<br>**កំណត់សំគាល់ៈ** | ១ ឆ្នាំ<br>**កំណត់សំគាល់ៈ** | មិនមានបញ្ជាក់ច្បាស់លាស់ក្នុងច្បាប់<br>**កំណត់សំគាល់ៈ** |

## ក្រសួងពាណិជ្ជកម្មផ្ដល់ជូនប្រភេទអាជ្ញាប័ណ្ណរួមមានៈ

| ប្រភេទអាជ្ញាប័ណ្ណ | អាជីវកម្មប្រភេទណាគួរតែដាក់ពាក្យសុំអាជ្ញាប័ណ្ណនេះ? | តើអាជ្ញាប័ណ្ណនេះប្រើដើម្បីគោលបំណងអ្វី? | តើឯកសារអ្វីខ្លះតំរូវអោយភ្ជាប់ជាមួយ? | តើត្រូវចំណាយរយៈពេលប៉ុន្មានដើម្បីធ្វើអាជ្ញាប័ណ្ណនេះ? | តើពេលណាទើបអាជ្ញាប័ណ្ណអស់សុពលភាព? | តើត្រូវបង់ប្រាក់ប៉ុន្មាន? |
|---|---|---|---|---|---|---|
| វិញ្ញាបនប័ត្របញ្ជាក់ការចុះបញ្ជីពាណិជ្ជកម្ម | រាល់ក្រុមហ៊ុនទាំងអស់ដែលតំរូវអោយបង់ពន្ធលើប្រាក់ចំណេញ | ដើម្បីបញ្ជាក់ភាពស្របច្បាប់ជានីតិបុគ្គលរបស់សហគ្រាសក្នុងការធ្វើពាណិជ្ជកិច្ច | ដាក់ពាក្យសុំនៅនាយកដ្ឋាននីតិកម្ម :<br>▪ ពាក្យសុំចុះបញ្ជី : ០៣ ច្បាប់<br>▪ អត្តសញ្ញាណប័ណ្ណ រឺ លិខិតឆ្លងដែន ( ថតចម្លង) របស់សមាជិកក្រុមហ៊ុនម្នាក់ៗ : ០៣ ច្បាប់<br>▪ រូបថតចំពីមុខរបស់សមាជិកក្រុមហ៊ុនម្នាក់ៗ ទំហំ (៤x៦)ៈ ០៣ សន្លឹក<br>▪ ឯកសារយោងពីធនាគារដែលមានបញ្ជាក់ពីដើមទុនទាបបំផុត ៤ លានរៀល : ០៣ ច្បាប់<br>▪ លក្ខន្តិកៈក្រុមហ៊ុន : ០៣ ច្បាប់ | យូរបំផុត១សប្ដាហ៍<br>**កំណត់សំគាល់ៈ** | ៣ ឆ្នាំ<br>**កំណត់សំគាល់ៈ** | ១០៥ ដុល្លាអាមេរិក<br>( ប្រកាសអន្តរក្រសួង)<br>**កំណត់សំគាល់ៈ** |
| វិញ្ញាបនប័ត្រចុះបញ្ជីម៉ាក ពាណិជ្ជសញ្ញា | គ្រប់ប្រភេទអាជីវកម្មទាំងអស់ | ផ្ដល់វិញ្ញាបនប័ត្រការពារម៉ាកពាណិជ្ជសញ្ញា | ដាក់ពាក្យសុំនៅនាយកដ្ឋានកម្មសិទ្ធិបញ្ញា :<br>▪ ពាក្យសុំចុះឈ្មោះ : ០១ច្បាប់<br>▪ សិទ្ធិប្រើប្រាស់ ផ្លាក សញ្ញាពាណិជ្ជកម្ម ដោយមានការបញ្ជាក់ពីមេធាវី រឺ សារការីសាធារណ : ០១ ច្បាប់<br>▪ ផ្លាកសញ្ញាគំរូ : ១៥ គំរូ | ៣ ខែ<br>**កំណត់សំគាល់ៈ** | មានសុពលភាពរយៈពេល១០ឆ្នាំ ប៉ុន្តែត្រូវរាយការណ៍ទៅនាយកដ្ឋានរៀងរាល់ ៥ឆ្នាំម្ដង<br>**កំណត់សំគាល់ៈ** | ▪ កំរៃដាក់ពាក្យ : ២០.០០០រៀល<br>▪ កំរៃចុះបញ្ជី : ១៨០.០០០រៀល<br>▪ ការបោះពុម្ពផ្សាយនឹងកំណត់ពេលក្រោយ<br>**កំណត់សំគាល់ៈ** |

| | | | | | | |
|---|---|---|---|---|---|---|
| **វិញ្ញាបនប័ត្រប្រភពដើមទំនិញ, វិក្កយប័ត្រពាណិជ្ជកម្ម និង អាជ្ញាប័ណ្ណនាំទំនិញចេញ** | អាជីវកម្មនាំចេញទៅសហគមន៍អឺរ៉ុប, អាមេរិក និង កាណាដា | ដើម្បីបញ្ជាក់ពីផលិតផលដើមដែលជាតម្រូវការរបស់សហគមន៍អឺរ៉ុប និងលិខិតនាំចេញ ដែលជាតំរូវការរបស់អាមេរិក។ កាណាដាទាមទារបន្ថែម Bill of Lading និងការប្រកាសប្រតិវេទន៍ពីស្ថាប័នគយ ហើយនិងវិញ្ញាបនប័ត្រពីនាយកដ្ឋានកាំកុងត្រូល | ដាក់ពាក្យសុំនៅនាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម (GSP)<br>▪ ពាក្យសុំវិញ្ញាបនប័ត្របញ្ជាក់ពីប្រភពដើមទំនិញ (C/O) : ០១ ច្បាប់<br>▪ វិក្កយប័ត្រ : ០១ ច្បាប់<br>▪ Packing List : ០១ ច្បាប់<br>▪ កិច្ចសន្យាលក់ និង/រឺ ការបញ្ជាទិញពីអ្នកនាំចូល : ០១ ច្បាប់<br>▪ វិញ្ញាបនប័ត្របញ្ជាក់ពីការផលិតដែលចេញដោយក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល : ០១ ច្បាប់<br>▪ ពង្រាងវិញ្ញាបនប័ត្របញ្ជាក់ពីប្រភពដើមទំនិញកម្ពុជា : ០១ ច្បាប់<br>▪ ពង្រាងវិក្កយប័ត្រពាណិជ្ជកម្ម : ០១ច្បាប់<br>▪ ពង្រាងអាជ្ញាប័ណ្ណនាំទំនិញចេញ : ០១ច្បាប់<br>▪ បង្កាន់ដៃដែលចេញដោយនាយកដ្ឋានរដ្ឋបាលនៃក្រសួងពាណិជ្ជកម្មសំរាប់ចំណាយលើពាក្យសុំ, អាជ្ញាប័ណ្ណនាំចេញ និងវិក្កយប័ត្រពាណិជ្ជកម្ម : ០១ ច្បាប់ | ៣-៤ សប្តាហ៍<br><br>**កំណត់សំគាល់:** | ប្រើបានតែមួយលើក<br><br>**កំណត់សំគាល់:** | ▪ គំរូពាក្យសុំវិញ្ញាបនប័ត្របញ្ជាក់ពីប្រភពដើមទំនិញ : ៣០ដុល្លាអាមេរិក<br>▪ ពាក្យសុំវិញ្ញាបនប័ត្របញ្ជាក់ពីប្រភពដើមទំនិញ : ៥០ ដុល្លាអាមេរិក<br>▪ អាជ្ញាប័ណ្ណនាំចេញទៅកាន់ប្រទេសកាណាដា : ៥០ ដុល្លាអាមេរិក<br>▪ វិក្កយប័ត្រពាណិជ្ជកម្ម : ១២០.០០០រៀល<br>**កំណត់សំគាល់:** |
| **អាជ្ញាប័ណ្ណនាំទំនិញចេញ** | អាជីវកម្មទាំងឡាយ ជាពិសេសរោងចក្រកាត់ដេរដែលនាំចេញទៅអឺរ៉ុប | ផ្តល់អាជ្ញាប័ណ្ណនាំទំនិញចេញ | ដាក់ពាក្យសុំនៅនាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស:<br>▪ ពាក្យសុំ : ០១ ច្បាប់<br>▪ វិក្កយប័ត្រ : ០១ ច្បាប់<br>▪ Packing List : ០១ ច្បាប់<br>▪ កិច្ចសន្យាលក់ និង/រឺ ការបញ្ជាទិញពីអ្នកនាំចូល : ០១ ច្បាប់<br>▪ ពង្រាងអាជ្ញាប័ណ្ណនាំទំនិញចេញ : ០១ ច្បាប់<br>▪ បង្កាន់ដៃ (១៥.០០០ រៀល) ដែលចេញដោយក្រសួងពាណិជ្ជកម្មសំរាប់ការចំណាយលើការធ្វើឯកសារ : ០១ ច្បាប់ | ៣-៤ សប្តាហ៍<br><br>**កំណត់សំគាល់:** | ប្រើបានតែមួយលើក<br><br>**កំណត់សំគាល់:** | ១៥.០០០ រៀល<br><br>**កំណត់សំគាល់:** |
| **វិញ្ញាបនប័ត្រចុះបញ្ជី សមាគមអាជីវកម្ម** | សមាគមអាជីវកម្ម | ផ្តល់វិញ្ញាបនប័ត្រចុះបញ្ជីសមាគមអាជីវកម្ម | ដាក់ពាក្យសុំនៅនាយកដ្ឋានពាណិជ្ជកម្មក្នុងស្រុក:<br>▪ លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់សមាគមៈ ០១ច្បាប់<br>▪ កំណត់ហេតុអង្គសន្និបាតបង្កើតសមាគមៈ០១ច្បាប់<br>▪ អត្តសញ្ញាណប័ណ្ណ រឺលិខិតឆ្លងដែនរបស់ប្រធានសមាគម (ថតចំលង)ៈ ០៣ ច្បាប់<br>▪ រូបថត (៤x៦)ៈ ០៣ សន្លឹក<br>▪ គំរូត្រា និងហត្ថលេខាប្រធានសមាគម : ០១ ច្បាប់<br>▪ ពាក្យសុំផ្សាយក្នុងសារពត៌មានជាផ្លូវការៈ ០១ច្បាប់<br>▪ កម្មសិទ្ធិផ្ទះជាទីតាំងសមាគម រឺកិច្ចសន្យាជួលផ្ទះជាទីតាំងសមាគម (ថតចំលង)ៈ០១ច្បាប់ | ៣-៤ សប្តាហ៍<br><br>**កំណត់សំគាល់:** | មិនមានការបញ្ជាក់ច្បាស់លាស់ក្នុងច្បាប់<br><br>**កំណត់សំគាល់:** | មិនមានការបញ្ជាក់ច្បាស់លាស់ក្នុងច្បាប់<br><br>**កំណត់សំគាល់:** |

**សំរាប់ពត៌មានបន្ថែមស្តីពីសេវាកម្មផ្តល់អាជ្ញាប័ណ្ណទាំងនេះ សូមទាក់ទងតាមលេខ 016 830 323/012 816 663**

**ក្ការពត៌មានស្តីពីការផ្តល់សេវាកម្មអាជ្ញាប័ណ្ណនេះ រៀបរៀងឡើងដោយមានកិច្ចសហការជាមួយក្រសួងពាណិជ្ជកម្ម និងសមាគមអាជីវកម្មខ្នាតតូចបំផុត ខ្នាតតូច និងមធ្យម**

**ដោយមានការគាំទ្រពី អង្គការមូលនិធិអាស៊ី និងវិទ្យាស្ថានកម្ពុជា ដើម្បីសិក្សាការអភិវឌ្ឍន៍**

**ប្រភពៈ ក្រសួងពាណិជ្ជកម្ម និងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**

**ក្ការពត៌មាននេះបោះពុម្ពផ្សាយនៅឆ្នាំ ២០០៨**